# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសជាមួយ នុត នៅ ភេទប្រុស អាយុ៦៥ឆ្នាំ
## នៅភូមិអង្ករនាប ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ
## មុខងារសម័យខ្មែរក្រហមៈ គណៈឃុំ
## នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥
## សម្ភាសដោយៈ ជួង សុភារិទ្ធ
## សរុបៈ ១៩ទំព័រ

នៅៈ ខ្ញុំឈ្មោះ នុត នៅ ។

នៅៈ អាយុមកដល់ថ្ងៃនេះ ៦៥ឆ្នាំហើយ ។

នៅៈ បាទ! ស្រុកកំណើតកើតជានៅភូមិនិងតែម្តង ។

នៅៈ ពីមុន ខ្ញុំកើតនៅភូមិដំបូក៨ ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ តែបច្ចុប្បន្ននេះដំបូក៨ទៅជាភូមិអង្ករនាបទៅហើយ ក្នុងអង្ករនាបនិងវាមានអង្ករនាប, ត្រពាំងជាយ, អង្ករនាប និងត្រពាំងបន្ទី ៤ភូមិសរុបធ្វើតែមួយភូមិទេ បច្ចុប្បន្ននេះ ។

នៅៈ ឃុំត្រាំកក់ ស្រុកត្រាំកក់វិញ តាកែវ ។

នៅៈ បាទ! កាលពីមុនញ៉ែងញ៉ងហ្នឹងទាំងមូលតែដល់ពេលបច្ចុប្បន្ននេះបែកជាពីរ ញ៉ែងញ៉ងផង និងត្រាំកក់ផង ។

នៅៈ បច្ចុប្បន្ននេះខ្ញុំធ្វើស្រែនិងធ្វើអាចារ្យការ អ្នកមហា ហើយនៅវត្តជាអាចារ្យវង ហើយផ្នែករដ្ឋបាលនេះធ្វើមេភូមិរង ។ អាចារ្យការហ្នឹងកាលពីសង្គមចាស់មកម្ល៉េះ ក្រោយ៧៩ហ្នឹងជាប់គុក៥ឆ្នាំ ចេញពីគុកមកវិញបានធ្វើអាចារ្យហ្នឹងទៀត ។

ភារិទ្ធៈ អូ! ក្រោយ៧៩ជាប់គុកដែរអ៊ំ?

នៅៈ ជាប់គុក ។

នៅៈ អត់ទេ ជាប់នៅកោះអណ្តែត ខ្វះ៤ខែ៦ឆ្នាំ ខ្ញុំអត់រត់ហ្នឹងគេ អត់រត់ម៉ងព្រោះខ្ញុំកាលនោះខ្ញុំធ្វើល្អគ្រាន់តែបច្ចុប្បន្នហ្នឹងបើប្រៀបធៀប បើគិតជាភាគរយវាល្អប្រហែល៦០ អាក្រក់ប្រហែលជា ៤០ ហ្នឹងខ្ញុំអាចប៉ាន់ខ្លួនឯង អញ្ចឹងខ្ញុំអត់រត់ ហើយគេចាប់យកទៅដាក់គុករៀនសូត្រហ្នឹង៥ឆ្នាំ ៨ខែ យូរដែរ ។

នៅៈ ឃី! ដូចជាមិនចាំទេ ។

នៅៈ សឹកពីបួសមក អាយុ២៣ ហើយការអាយុបែប២៤-២៥អីហ្នឹងតាមស្មាន ។

នៅៈ បួសក្រោយពីឈប់រៀនទៅ បែប៥-៦វស្សាដែរទាំងនេន ទាំងកឹកនិង ឆ្នាំ៥៧-៥៨ ប្រលង certificate ហើយមកបួសហ្នឹង អាយុ២៣និងសឹក និងហើយ ការខ្ទង់អាយុ២៥ ។

នៅៈ នៅវត្តកោះក្អែក ។

នៅៈ នៅលិចនេះ ។

នៅៈ ឃុំត្រាំកក់នេះ ។

នៅៈ បានជាបួសនិងក្រោយពីចប់ការសិក្សាទៅ ប្រឡងទៅជាទៅកាលនោះគេហៅ Monitor អីហ្នឹង ធ្លាក់ទៅ ប្រលងទៅកំពង់កន្ទួតក៏ធ្លាក់អញ្ចឹងទៅ ជីវភាពក្រុមគ្រួសារហ្នឹងនៅតែម្តាយ នៅម្តាយក្រ អញ្ចឹងគ្មានលទ្ធភាព គ្មានលុយកាក់អីទៅរៀន មកអញ្ចឹងបានចូលសាងផ្នួសទៅ គោលបំណងនិង រៀនតែងារអត់ថវិការក្នុងគ្រួសារ ។

នៅៈ រៀនតាមលោក រៀនសាលាបាលីរងហ្នឹង រៀនបានសញ្ញាបត្របាលីរងហ្នឹងមួយហើយក៏ម្តាយ នេះក៏លំបាកក្នុងគ្រួសារ បង១រៀបការអស់ទៅក៏សឹកមកទៀត មករកប្រពន្ធហ្នឹង ។

ភារិទ្ធៈ ចុះគ្រួសារអ៊ំឈ្មោះអីដែរ?

នៅៈ ប៊ូ សោ ។

នៅៈ ៥៦ហើយ ។

នៅៈ នៅហ្នឹង ភូមិហ្នឹង ពីដើមភូមិនេះគេហៅភូមិត្រពាំងជាយនេះណា តែឥឡូវភូមិអង្គរនាបតែមួយ ។

នៅៈ កូនចៅខ្ញុំ៩នាក់ ប្រុស៧ ស្រី២ ឥឡូវនិងនៅតែ៨ទេ បាត់មួយបងបន្ទស់ ។

នៅៈ ឪពុកម្តាយស្លាប់អស់ហើយ ។

នៅៈ ឪពុកឈ្មោះ នុត ណុប ។

នៅៈ ម្តាយឈ្មោះ នុត ផែន ។

នៅៈ ហ៊ឺស! គាត់ឈឺកាលពីមុនហ្នឹងមក ។

នៅៈ ទេមិនចាំទេ កាលពីឪពុកស្លាប់ខ្ញុំនៅអាយុ១៥-១៦ឆ្នាំនៅឡើយ ហើយម្តាយនិងនៅទេឥឡូវនេះ តែអាយុ៨៧ហើយ ។

នៅៈ នៅដំបូក៨នេះ ។

នៅៈ បាទមួយ ឃុំតែមួយ ។

នៅៈ ខ្ញុំរាប់សិន បងប្អូនបង្កើតស្រី៤ ប្រុស៣ ទាំងអស់៧នាក់ ។

នៅៈ បងប្អូនស្លាប់ប៉ុល ពតមួយ ។

នោៈ បួនស្រីពៅ កាលនិងរឿងរ៉ាវអីគេយ៉ាងម៉េចយ៉ាងម៉ាទេ ទៅរកមិនឃើញ កាលហ្នឹងវាធ្វើពេទ្យនៅក្រុងព្រះសីហនុ វាធ្វើបុគ្គលិកពេទ្យហ្នឹង ហើយកាលពីគេចាប់រញ៉េរញ៉ៃយហ្នឹងក៏បាត់វាដែរទៅនិងបាត់ប្អូនពៅមួយ ក្រៅពីហ្នឹងនៅទាំងអស់ទេ ស្លាប់មួយ ប្រុសកាលពីរត់ហ្នឹង បើស្រីនោះប្រហែលគេយកហើយបើតាមដានមើល ពាក់ព័ន្ធនិងនយោបាយយ៉ាងម៉េចយ៉ាងម៉ា ហ្នឹងយើងមិនអាចដឹងដែរ គេមិនឲ្យដឹងផង ។

ប្រពន្ធៈ គេនៅកន្លែងធ្វើការនោះយកទៅបាត់ហើយ ដល់បាត់ម៉ងបានគេប្រាប់ម៉ង ។

នោៈ មុនឆ្នាំ៧០ និងដូចជាអត់មានរឿងរ៉ាវអីទេ ។

នោៈ បាទ! គ្មានរឿងរ៉ាវអីទេ ដឹងតែពីរឿងលន់ នល់ធ្វើរដ្ឋប្រហារសម្ដេចសព្វថ្ងៃហ្នឹងទៅ ខាងនេះមានខ្មែរក្រហមចូលមកតស៊ូហ្នឹងម៉ង ។

នោៈ អត់ទេ អត់ដឹងទេ យើងអ្នកស្រែ រឿងគេម៉េចហ្នឹងដឹង ។

នោៈ ពេលរដ្ឋប្រហារខ្ញុំនៅហ្នឹង កាលនោះខ្ញុំធ្វើមេភូមិដែរហ្នឹង ក្រោយការហើយខ្ញុំធ្វើមេភូមិកាលពីជំនាន់សង្គមរាស្ត្រនិយមនិងធ្វើមេភូមិនៅហ្នឹង ។

នោៈ គ្រួសារអត់ធ្វើអីទេ អត់ចេះអក្សរផង ។

នោៈ ក្រោយមកតាមតំបន់នេះជាតំបន់ដាច់ស្រយាល អញ្ចឹងមានតែខ្មែរក្រហមកាលហ្នឹងគេហៅថាខ្មែររំដោះណាំ ខ្មែរក្រហមដោះហ្នឹងចូលមកដល់អញ្ចឹងម៉ង គេចាត់តាំងជាក្រុមជាភូមិអញ្ចឹងទៅ កាលហ្នឹងមានអី អត់មានអីទេ មានតែទាហាននៅអគ្គតាសោមណោះ អញ្ចឹងឲ្យប្រឆាំងជាមួយនិងលន់នល់ គឺគាំទ្រសម្ដេចនរោត្តមសីហនុ ខាងនេះគេហៅថារណសិរ្សបង្រួបបង្រួមជាតិកម្ពុជា កាលពីជំនាន់នោះណា អញ្ចឹងរួមគ្នាជាមួយសម្ដេចឪប្រឆាំងជាមួយរបបលន់ នល់ តែប៉ុណ្ណឹង ។

នោៈ អត់ជម្លៀសទេ នៅហ្នឹង រៀបភូមិឃុំហ្នឹងម៉ងព្រោះកាលនិងជាតំបន់ដាច់ស្រយាល ។

នោៈ កាលហ្នឹងខ្ញុំអត់ធ្វើអីទេកាលពីជំនាន់ហ្នឹង ធ្វើប្រជាជន មានមេភូមិគេផ្សេងចាស់ៗ ។

នោៈ មេភូមិហ្នឹង អៀប ដោច, អង់ ឌុចហ្នឹងមេភូមិជំនាន់ហ្នឹង ហើយង៉ែត ងឹម នៅហ្នឹងគាត់ស្លាប់អស់ហើយ មេភូមិក្រោយមក ។

នោៈ អត់ទេ ឪ កាលពីចូលដំបូងណាំ ឌុច ហ្នឹងអត់មេភូមិទេ ។

នោៈ កាលនោះឲ្យរកស៊ីធម្មតា ហ្នឹងចូលមកគេឲ្យយើងធ្វើការងារឯកជនរកស៊ីដូចសព្វថ្ងៃអញ្ចឹង ប៉ុន្តែមានចលនាមួយបំផុសកំហឹងជាមួយហ្នឹងរបបលន់ នល់, ចេង ហេង, អ៊ិន តាំ អញ្ចឹងកូនចៅគេលះបង់ ធ្វើទ័ពប្រឆាំងហ្នឹងរបបលន់ នល់ហ្នឹងជាបន្តបន្ទាប់ទៅ ។

នោះ៖ ទៅឆ្នាំ ៧៥ ហើយ ក្រោយរំដោះ កូនហ្នឹងអាយុ១៥-១៦ឆ្នាំ ហើយគេបញ្ជូនទៅបូព៌ាទៅ កំពង់ចាម បញ្ជូនទៅហ្នឹងហើយបាត់ទៅ ប៉ុន្តែមុនហ្នឹងឆ្នាំ៧៨ ហ្នឹងនៅទេមានមកម្តង ដល់៧៩ហ្នឹងបាត់គេ ថាបាត់ សួរគេអ្នកទៅជាមួយគេថាបាត់តែម្តង មិនដឹងបាត់មូលហេតុអីមិនដឹងដែរទេ ។

នោះ៖ ភូមិហ្នឹងតែម្នាក់ឯងទេ តែមាននៅខាងញ៉ែងញ៉ង មាននៅខាងឃុំគុសទៅជាមួយ ។

នោះ៖ នៅកំពុងចាមណោះ អត់ស្គាល់ទេ ។

នោះ៖ បាទ ទៅកំពង់ចាម ។

នោះ៖ អ្នករើសមិនស្គាល់ទេ ស្រេចតែគេហៅទៅ ខាងលើគេហៅថា អញ្ចឹងដែនរបស់មជ្ឈិមអី ឡើងទៅនិងគេចែកតាមមុខសញ្ញាទៅ ។

នោះ៖ ហឺ មិនដឹងព្រោះខ្ញុំជូនទៅដល់កន្លែងមន្ទីរស្រុក ។

នោះ៖ ប្អូនពៅហ្នឹងតាំងពីឆ្នាំ៧៨ ។

នោះ៖ បាទ! គេរើសដែរ ទៅតាមអញ្ចឹងគេទៅធ្វើពេទ្យ ពេទ្យហ្នឹងនៅគ-៣ ពីដើមនៅគ-៣នៅតាកែវ ហើយផ្លាស់ទៅកំពង់សោមទៅ ឯករាជ្យហើយ អញ្ចឹងឆ្នាំ៧៨ហ្នឹងនៅទេ ដល់ចុង៧៨ស្រាប់តែបាត់ខ្លួនទៅមិនដឹងទៅណា ហ្នឹងមិនដឹងមូលហេតុអីទេ តែកាលហ្នឹងនៅក្រុងកំពង់សោមគេមានសម្រិតសម្រាំង អញ្ចឹងដោយទាំងមេទាំងកូនហ្នឹងទៅបណ្តើរៗទៅ មិនដឹងឲ្យទៅណាមិនហ៊ានសន្និដ្ឋានព្រោះមិនឃើញ និយាយទៅវាខុស តែអាចបាត់ជីនាន់ ។

នោះ៖ ឈ្មោះ ណុប សុជាត អាយុ១៥ទេ នៅក្មេងដែរ ។

ភារិទ្ធ៖ ចុះកូនដែលទៅធ្វើពេទ្យ?

នោះ៖ ឈ្មោះ ណុប សារុន ។

នោះ៖ ពេលទៅនោះវាមានគ្រួសារទៅហើយ អាយុ១៨-១៩ឆ្នាំហើយយ៉ាង ។

នោះ៖ គ្រួសារធ្វើទ័ពដែរ តែឥឡូវស្លាប់បាត់អស់ហើយ ។

នោះ៖ អត់ដឹងទេកាលពីជំនាន់នោះ ។

នោះ៖ គេរៀបឲ្យ តាមស្នានទេណ៉ប្រហែលជា៧៧ ។

នោះ៖ មកប្រហែលជា២ដងដែរនិង ហើយខ្ញុំនិងទៅដល់ម្តងដែរនៅស្ទឹងហាវនេះ ។

នោះ៖ មានទ័ពគេមកជាមួយគ្នា គេយកឡានមក កាលនោះគេសុំជាគោ ជ្រូកនាយអាយ មាន់ទាអី ទ័ពកាលពីទៅនិងមុនដំបូង អញ្ចឹងឡានគេមកទៅជាមួយឡានគេទៅ ។

នោះ៖ ឆ្នាំ៧៧ កាលនោះការហើយៗ ចុង៧៧ ។

នោះ៖ ពីមុនមកខ្ញុំដោយគេបំផុសឲ្យមានកំហឹងប្រឆាំងជាមួយលន់ នល់ហ្នឹង ខ្ញុំទៅធ្វើទ័ពហ្នឹងចុងឆ្នាំ៧៣ ក្រោយពីហ្នឹងមកចេះតែនៅហ្នឹងមុខអញ្ចឹងទៅ ធ្វើទ័ពហ្នឹងក្រោយឯករាជ្យដួលរលំរបបលន់ នល់

ហើយ គេចាត់តាំងខ្ញុំឲ្យមកធ្វើសមាជិកឃុំ ធ្វើសមាជិកឃុំពាក់កណ្តាលឆ្នាំ៧៦ ។ ក្រោយមកគេឲ្យធ្វើប្រធានឃុំនៅស្រែរនោងនេះ ។

នោះ: បាទ! ប្រធានឃុំនៅស្រែរនោង កាលហ្នឹងធ្វើប្រធានឃុំស្រែរនោងហើយមានការរកាំរកូស ព្រោះខ្ញុំអ្នកការរៀបចំដោះស្រាយជីវភាពជូនប្រជាពលរដ្ឋ ប្រជាពលរដ្ឋមានការតស៊ូ គេផ្លាស់មកខាងអន្លង់តាសោម មកឃុំអន្លង់តាសោមនេះ ប្រធានឃុំនៅហ្នឹងកាលនោះគេដោះស្រាយមិនចេញ គេយកខ្ញុំបាន២ខែ បែកអញ្ចឹងទៅ ។

នោះ: បែកអញ្ចឹងខ្ញុំអត់រត់ទេ ព្រោះមូលហេតុដោយខ្ញុំមិនរត់ព្រោះខ្ញុំវាអស់ជំនឿ ដោយម្យ៉ាងគេថាខ្ញុំហ្នឹងវាបញ្ចុះបញ្ចូល ពីមុនមកគេសរសើរដល់ខ្ញុំមកនៅអន្លង់តាសោមនេះ គេថាខ្ញុំអីអញ្ចឹងទៅ មានការស្រលាញ់នារីអីអញ្ចឹងទៅ ចិត្តខ្ញុំអត់ដែលមានសោះ ដល់អញ្ចឹងអត់រត់ រត់ដែររត់ក្បែរខ្ញុំហ្នឹងវៀងមកចូលផ្ទះវិញ ភូមិនៅហ្នឹង ចូលវិញគេយកទៅដាក់គុកទៅ ។

នោះ: បាទ! មាន មានមកច្រើនដែរណា៎ ។

នោះ: មកពីភ្នំពេញ, តាកែវ, កំពតអីខ្លះទៅតាមកន្លែង ។

នោះ: ពីដំបូងគេហៅថាផ្ញើទុកទេ មកដល់ដំបូងដោយសារខ្វះជីវភាព ខ្វះទីលំនៅ កន្លែងស្នាក់នៅបានត្រឹមត្រូវ គេទុកដូចជាផ្ញើនៅជាមួយយើងអញ្ចឹងទៅ ហូបចុកអីជាមួយគ្នា អញ្ចឹងកាលនោះគេធ្វើជាក្រុមប្រវាស់ដៃហើយ

នោះ: បាទ! មានគេសួរដែរ មិនអត់ទេ ភូមិឃុំអីគេសាកសួរអញ្ចឹងទៅ មាន ។

ភារិទ្ធ: ចុះគេសួរប្រវត្តិរូបកាលនិងគេសួរដើម្បីអី អ៊ីមានដឹងទេ?

នោះ: បាទ! អត់ដឹងទេ ។

នោះ: ពីមុនមកនៅជាមួយគ្នា ធ្វើការជាមួយគ្នា តែក្រោយមក ឆ្នាំខ្ទង់ ៧៧-៧៨គេរៀប ហ្នឹងគេរៀបហើយ គេរៀបប្រជាជនពេញសិទ្ធិ ប្រជាជនត្រៀម គេយកផ្ញើអីអញ្ចឹងមានគេរៀបតើ គេរៀបអញ្ចឹងតែការនៅ នៅក្រុមដោយខ្លួន តែធ្វើការរួមគ្នា ធ្វើការងារប្រចាំថ្ងៃហ្នឹងរួមគ្នា ។

នោះ: ខ្ញុំកាលនោះគេថាអញ្ចឹងថាតាមគេទៅហ្នឹង ពេញសិទ្ធិហ្នឹងគេរកប្រជាជនដែលរស់នៅមូលដ្ឋានហ្នឹងយូរ ហើយ អញ្ចឹងប្រជាជនត្រៀមនិងពាក់ព័ន្ធថាមានបងប្អូនគ្រួសារអីហ្នឹងគេយកទៅរៀនសូត្រអីហ្នឹងគេហៅថាត្រៀមទៅ ឯប្រជាជនផ្ញើ ហ្នឹងប្រជាជនដែលមកពីទីក្រុង ។

នោះ: និងហើយ និងត្រៀម ។

នោះ: ថ្មីសុទ្ធ ។

នោះ: ការងារប្រវាស់ដៃហ្នឹងមានតែការងារដកស្ទូងធ្វើស្រែទេ ហើយក្រៅពីហ្នឹងមកយើងរកស៊ីឯកជនបាន ដាំដំណាំអីហូរហែអញ្ចឹងទៅ ហើយដល់ពេលរដូវស្ទូងដកអីអញ្ចឹង មានប៉ុន្មាន ឧទាហរណ៍ថា

មួយផ្ទះមានប៉ុន្មាននាក់ចូលប្រឡូកក្នុងការងារពលកម្ម និងស្ទូងដកអញ្ចឹងទៅ កម្លាំងទីមួយហ្នឹងគឺស្ទូងដកហើយ ច្រូតកាត់ហើយ បោកបែនដាក់ជង្រុក គេចែកផលទៅតាមប្រភេទហ្នឹង ឧទាហរណ៍ថាយើងនៅតូច កូនយើងមានតូចច្រើន ហ្នឹងគេថាមិនកម្លាំងស្រួចទេ កម្លាំងបន្ទាប់បន្សំ ហ្នឹងអត់ធ្វើការអី គេចែកផលទៅតាមហ្នឹង ឯកម្លាំងទីមួយហ្នឹង គេចែកផលគឺឧទាហរណ៍ទេណា៎ ។

នោះ: បើម្នាក់១០ថាំងទៅជា១០ថាំងស្មើរគ្នាអញ្ចឹងស្រូវ យើងយកមកតម្កល់ទុកក្នុងជង្រុករបស់យើងមកដោះស្រាយជីវភាពគ្រួសារ ខ្វះខាតបន្តិចបន្តួចហ្នឹងយើងដោះស្រាយដាំដំណាំរួមផ្សំទៅហ្នឹងគេថាប្រវាស់ដៃ ចែកផលហ្នឹងទៅតាមកម្លាំងពលកម្ម ។

នោះ: រួមហ្នឹងបើគិតទៅគេចង់រៀបឆ្នាំ៧៨ហើយទេ កាលពីហូបរួមបណ្តើរតិចតួចៗណា៎ ដល់ក្រោយរំដោះហ្នឹងបានគេទូទៅ ពីមុនមកភូមិខ្លះគេសួរស្ម័គ្រចិត្ត ក្នុងឃុំនីមួយៗគេសួរថាឃុំណាដែលហៅថាបដិរូបហូបរួមនោះ អញ្ចឹងគេធ្វើតាមភូមិណាដែលអាចធ្វើបាន ប៉ុន្តែក្រោយ៧៥ដែលរំដោះហើយគឺរួមទូទាំងឃុំតែម្តង រួមមួយកងគេរៀបចំហូបបាយមួយកន្លែងៗ ។

នោះ: ឆ្នាំប្រហែលជាក្រោយបែក ។

នោះ: បែកប្រហែលជា២-៣ខែមកគេរៀបចំឲ្យហូបរួមហើយ ព្រោះកាលពីមកដំបូងនៅប្រវាស់ដៃនៅឡើយទេ ប្រជាជនដែលជម្លៀសមកពីភ្នំពេញ នៅក្រុមប្រវាស់ដៃ ចែកផលហូប អញ្ចឹងដែរ ដល់ឆ្នាំខ្ទង់៧៦គេរៀបជាសហករណ៍ហូបរួម គិតក្នុងមួយកងហ្នឹងមាន១០០ ឬជាង១០០គ្រួសារហូបមួយកន្លែង ប្រហែលជា៧៦ហើយចាំមិនច្រាកដដែរ ។

នោះ: បាទ! មានខ្លះមួយចំនួនធំដូចជាចាន ស្លាបព្រា ឆ្នាំង គេប្រមូលយកទៅដាក់សហករណ៍ ដាក់រោងបាយរួម តែមានខ្លះមានលាក់ទុកខ្លះដែរ មានអ្នកខ្លះដែរ តែប្រមូលហ្នឹងមានតែចាន ស្លាបព្រាយកទៅដាក់ក្នុងចង្ក្រានរួមទាំងអស់ ។

នោះ: គ្រឿងអលង្ការគេអត់មានប្រមូលទេ បើគោគេដាក់ជាសម្បត្តិរួម មាន់ ទា ជ្រូកអីនិងគេដាក់រួមអស់ហើយ តែគ្រឿងអលង្ការកាលនោះលែងឃើញមានពាក់អី លែងប្រើប្រាស់អីទៅ ទាំងអស់គ្នាមិនដឹងយ៉ាងម៉េចយ៉ាងម៉ា អត់មានមានប្រមូលជាមាសជាប្រាក់អីអត់ទេ បើឆ្នាំចាននិងឃើញប្រមូល ។

នោះ: បាទ! ហូបហ្នឹងហូបដូចគ្នា ការងារហ្នឹងធ្វើដូចគ្នា ហូបជាមួយគ្នាអញ្ចឹងទៅ តាមរោងបាយនីមួយៗហូបដូចគ្នា កំណត់តែមួយឃុំកំណត់យ៉ាងម៉េច របបដូចគ្នា ធ្វើការដូចគ្នា មិនថាប្រជាជនពេញសិទ្ធប្រជាជនត្រៀម ប្រជាជនផ្ញើអីទេ គឺធ្វើការរួមទាំងអស់គ្នា ស្ទូងដកអីជាមួយគ្នាទៅ ទៅជីកប្រឡាយជាមួយគ្នាទៅ ទៅធ្វើការងារអីដែលពាក់ព័ន្ធហ្នឹងភូមិទៅជាមួយគ្នា រាប់អានគ្នា សាមគ្គីគ្នាតែដោយឡែកគឺរស់នៅកងផ្សេង ។

នៅៈ បាទ! ធ្វើការធ្វើរួម ធ្វើមួយឃុំម៉ង ក្នុងមួយឃុំនិងគឺរួម ឧទាហរណ៍ថាទៅធ្វើប្រឡាយអញ្ចឹងទៅ គេចាត់តាំងកម្លាំងភូមិ កងនេះយកប៉ុន្មានៗ កងនេះខាងជីប៉ុន្មាន កងនេះខាងធ្វើស្រែប៉ុន្មាន គេរើសយកទៅតាមហ្នឹង ។

នៅៈ មាន មិនអត់ទេ នារីផ្សេងទេ មួយកងទៅ គេហៅថាកងប្រមូលផ្ដុំនារី កងប្រមូលផ្ដុំយុវជន តែការងារធ្វើជាមួយគ្នានៅកង កូនចៅអីគេរៀបនៅកង កូនចៅដែលមានអាយុល្មមចេញពីម្ដាយពីម្ដាយឪពុកនិងគេយកទៅដាក់នៅកង ។

នៅៈ កូនដែលនៅតូចនៅជាមួយមាតាបីតា ធំល្មមទៅកង គឺទៅកងកុមារ ។

នៅៈ ម្ដាយទៅធ្វើការគេមានអ្នកមើលកូន អ្នកដូចចាស់ធ្វើការកម្លាំងពលកម្មហ្នឹងមិនអាចបាន គេឲ្យនៅមើលកូនអញ្ចឹងទៅ ពេលអុឺមគេឲ្យទៅអុឺមអញ្ចឹងទៅ ប៉ុន្តែម្ដាយដែលនៅបំបៅកូនហ្នឹងគេឲ្យធ្វើការងារជិតៗភូមិទេ មិនឲ្យទៅឆ្ងាយទេ ។

នៅៈ ឲ្យធ្វើដូចតែគ្នា ឲ្យធ្វើអញ្ចឹងដូចតែគ្នា បើថាទៅស្ទូង ស្ទូងនិងគេទៅ អត់មាននៅទំនេរទេ ។

នៅៈ ការហូបចុកហ្នឹង វាសំខាន់ទៅតាមមូលដ្ឋានមួយៗទេ ហ្នឹងមិនអាចជម្រាបជាទូទៅបានទេ មូលដ្ឋានខ្លះគេខាងឃុំគេចេះរៀបចំ ភូមិឃុំដោះស្រាយជីវភាព ការហូបមានការហូបបបរអីខ្លះអញ្ចឹងទៅ ដាំបាយអីខ្លះអញ្ចឹងទៅ បួនដប់ថ្ងៃគេធ្វើជាម្ហូប ហៅថារៀនសូត្រមានសាច់គោ សាច់ជ្រូកអីហូបសប្បាយមួយថ្ងៃ កំណត់១០ថ្ងៃគេជួបជុំគ្នា គេថាធ្វើសន្និបាតម្ដង ហូបរួមគ្នា មានសាច់គោសាច់ជ្រូក តែកន្លែងខ្លះវាមានអាខ្វះខាតអញ្ចឹងទៅ ចំពោះកន្លែងខ្ញុំគេដោះស្រាយបានគួរសមដែរ មានម្ហូបអីអញ្ចឹងទៅ មានបន្លែមអីអញ្ចឹងទៅ និយាយរួមគឺឃុំត្រាំកក់ទាំងមូលមិនជាបញ្ហាទេខាងហូប គឺមិនជួបការលំបាកទេ ។

នៅៈ បាទ! ខ្ញុំនៅស្រែរនោង ។ នៅស្រែរនោងហ្នឹងក៏មិនបញ្ហាដូចឃុំត្រាំកក់ដែរ ព្រោះមូលដ្ឋានគ្រឹះកន្លែងនោះគឺថាធ្វើស្រែកសិកម្មហ្នឹងបានផលច្រើនដែរ អញ្ចឹងយើងត្រៀមសំរាប់ប្រជាជនសំខាន់ហៅថាយើងមានទូរលេខច្បាស់ ឧទាហរណ៍ថាប្រជាជនៅក្នុងឃុំហ្នឹង ឧទាហរណ៍ថា៥០០០នាក់អីអញ្ចឹងទៅ យើងធ្វើស្ថិតិក្នុងការហូបហ្នឹងឲ្យច្បាស់ ក្នុងមួយថ្ងៃយើងត្រូវហូបប៉ុន្មានយើងឲ្យមានទុនរបស់ យើងនៅក្នុងជង្រុកហ្នឹងប៉ុន្មាន អញ្ចឹងទៅស្រែនរនោងពីមុនដែលខ្ញុំធ្វើហ្នឹងមានការខ្វះខាត ក្រោយមកពេលដែលខ្ញុំធ្វើមិនជាខ្វះខាតអីទេ មិននិយាយកុហកអីទេ គឺដោះស្រាយរួច ។

នៅៈ រឿងនេះបើតាមទស្សនៈខ្ញុំយល់ថាគេយកទៅរៀនសូត្រហើយ តែដល់នេះបាត់ៗរហូត តែដល់បាត់មិនដឹងយ៉ាងម៉េចបានជាគេយកទៅអប់រំរៀនសូត្រ កែប្រែយ៉ាងម៉េចយ៉ាងម៉ា ដល់នេះមាន

បាត់អីអញ្ចឹងខ្លះដែរ តែត្រឹមខ្ញុំធ្វើ ឡើងទៅធ្វើដូចជាមិនសូវ មិនមានបាត់អីទេ ព្រោះខ្ញុំមិនរវាយបញ្ជូនដែរ ពិនិត្យអប់រំបណ្តើរៗ ដោះស្រាយបណ្តើរៗ ។

នៅៈ ធ្វើការតាមកងគេកំណត់ថា១០ថ្ងៃមកជួបគ្នាម្តង ដូចថាទៅធ្វើការអញ្ចឹងប្រពន្ធធ្វើផ្សេង ប្តីធ្វើផ្សេង អញ្ចឹង១០ថ្ងៃគេមកជួបគ្នានៅគ្រួសារម្តង ហើយបានបែកមុខសញ្ញាគ្នាមកធ្វើតាមកន្លែងផ្សេងៗគ្នាទៅ តែកន្លែងខ្លះដូចនៅខ្ញុំខាងស្រែននោងនេះអត់មានកន្លែងទៅសំរាកឆ្ងាយទេ យប់មកផ្ទះវិញទាំងអស់គ្នា ថ្ងៃចេញទៅធ្វើ យប់មកផ្ទះ តែកន្លែងផ្សេងតាមឃើញ មានឃើញសំរាកតាមវាលស្រែមានអី មានរោងតូចៗអីអញ្ចឹងទៅ ១០ថ្ងៃគេឲ្យទៅជួបម្តង ដូចឃុំឆ្ងាយៗ ដូចឃុំស្រែរនោង ឃុំវានៅជិតៗ ធ្វើតែថ្ងៃ យប់មកផ្ទះវិញ ។

នៅៈ នេះការធ្វើខុសហ្នឹង ជំនាន់នោះសំខាន់អ្នកដែលប្រឆាំង អ្នកដែលមិនពេញចិត្តគេថាហៅអ្នកហ្នឹងទៅរៀនសូត្រហើយ ប្រឆាំងហ្នឹងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គេយកទៅរៀនសូត្រហើយ ប្រឆាំងយ៉ាងម៉េច ឧទាហរណ៍ថាមានការនិយាយថាអញ្ចេះថាអញ្ចុះអី មានអ្នករាយការណ៍អីទៅគេយកទៅហើយ ។

នៅៈ ការធ្វើខុសហ្នឹងមនុស្សម្នាក់ៗមានការធ្វើខុសដូចតែគ្នាខ្លះអញ្ចឹង ដូចខ្ញុំជម្រាមខាងដើមហើយ ពីមុនមកគេថាខ្ញុំហ្នឹងធ្វើការល្អ ដឹងទុក្ខធុរៈ ចេះដោះស្រាយជីវភាពជូនប្រជាពលរដ្ឋ ប្រជាជននៅក្នុងឃុំហ្នឹងគេថាខ្ញុំធ្វើល្អ ដល់ក្រោយមកគេថាខ្ញុំហ្នឹងមានខូចនារីអញ្ចឹង គេលែងទុកចិត្តអីអញ្ចឹង តែតាមពិតអត់ផង តែមានអ្នករាយការណ៍បន្ថុច តែគេទុកក្នុងនាមថាពិនិត្យ ហើយក្រោយមកបែកទៅខ្ញុំអត់ទៅជាមួយគេខ្ទាច ខ្ទាចទៅដល់ព្រៃទៅ គេថាឯងហ្នឹងអញ្ចេះអញ្ចុះ គេប្រឡេះចោល អញ្ចឹងរត់មក នៅនេះម៉ងទៅ ចេញពីនោះមកនៅហ្នឹង ។

នៅៈ ៣-៤នាក់ណោះ មានប្រធានឃុំ អនុប្រធានឃុំ សមាជិក ទី១ ទី២ ទី៣អញ្ចឹងមាន ។

នៅៈ បាទ! មានចាំដែរតើ ។

នៅៈ បន្ទាប់ពីខ្ញុំឈ្មោះ តាភៅ គាត់ស្លាប់ហើយ ។

នៅៈ បាទ! នៅខាងកោះក្អែក ឃុំស្រែននោងហ្នឹងដែរ ។

នៅៈ នេះនៅនេះ ឃុំជាប់គ្នា ។

នៅៈ បាទ! គាត់ស្លាប់អស់ហើយ ស្លាប់ដោយជម្ងឺ ហើយបន្ទាប់មកមានតាសន តាសនហ្នឹងគាត់ស្លាប់ដែរ ហើយនៅភូមិត្រពាំងឫស្សីនេះ ឃុំត្រាំកក់ ។

នៅៈ បាទ! ក្រោយ៧៩ ស្លាប់ខ្ទង់ឆ្នាំ៨៧-៨៨ហើយ ហើយម្នាក់ទៀតឈ្មោះឆន នៅត្រពាំងធំសមាជិកបាត់ខ្លួនទល់ឥឡូវមិនដឹងនៅឯណា មិនដឹងគេនៅទល់ដែនឬអី ។

នៅៈ មិនដឹងនៅរស់ ឬអី ។

នៅៈ បាទ! តែប៉ុណ្ណឹង ។

នៅៈ យូរពេកហើយ ។

នៅៈ មានសហករណ៍ភូមិថ្មី, ភូមស្រែថ្កុក, ភូមិស្រែននោង, ភូមិត្រពាំងននោង, ភូមិចិន និង ភូមិអន្លុ ស្វាយ មានប៉ុណ្ណឹង ។

នៅៈ បាទ! ស្គាល់ ។

នៅៈ មកដល់ឥឡូវអត់សូវចាំទេ ខ្លះស្លាប់បាត់ទៅ ។

នៅៈ បាទ! សហករណ៍មួយនៅភូមិចិនឈ្មោះ តាហេង ។

ភារិទ្ធៈ មួយសហករណ៍និងគេឲ្យកាន់ប៉ុន្មាននាក់?

នៅៈ ៣នាក់ ។

នៅៈ មានប្រធាន អនុប្រធាន និង សមាជិក ។

នៅៈ បាទ ហើយភូមិថ្មីនិងឈ្មោះ អីទេ បែកគ្នាហើយភ្លេច ។

នៅៈ អត់ដែលឃើញដង ហើយភូមិស្រែថ្កុកឈ្មោះម៉ាង ស្លាប់បាត់ទៅហើយ ។

នៅៈ មិនដឹងយ៉ាងម៉េចទេ ។

នៅៈ បាទ! ក្រោយ៧៩ឈឺ ហើយភូមិស្រែននាងហ្នឹងឈ្មោះ តាឡុច ស្លាប់ដែរ ហើយភូមិក្រាំង ស្វាយ ឈ្មោះថន ស្លាប់ដែរ ភូមិថ្មីហ្នឹងឈ្មោះសុខ ស្លាប់ហើយខ្មែរក្រហមបាញ់ ។

នៅៈ ក្រោយ៧៩ទាំងអស់ ហើយធ្វើមេភូមិយើងដំបូងនេះ ហើយខ្មែរក្រហមពីព្រៃមក គេបាញ់ស្លាប់ ទៅ ។

នៅៈ បាទ! នៅតាហេងនៅរស់តែតាហេងហ្នឹងមួយទេ ។

ភារិទ្ធៈ នៅឯណាវិញ?

នៅៈ ឥឡូវនៅ ។

នៅៈ ខាងកើតគោកពាង ព្រៃផ្គរ តែភូមិព្រៃស្វឹកឬភូមិអីទេ មិនដឹងទេ ។

នៅៈ ស្រុកទ្រាំង ។

នៅៈ ស្លាប់អស់ហើយ ។

នៅៈ ចៅហ្វាយស្រុកហ្នឹងលើខ្ពស់ទៀត នៅត្រឹមឃុំមិនអាចស្គាល់បានទេ ជួបម្តងម្កាលពេលទៅរៀន សូត្រអី តែស្រុកនេះកាលហ្នឹងធ្លាប់ឃើញអីមានថ្នាក់ដឹកនាំស្រុកនិងមានការផ្លាស់ប្តូរច្រើនដែរ តែយើងនិយាយចុងក្រោយចុះណ៎ា ។

នៅៈ ចុងក្រោយមាននារីមួយនៅជាងទង ។

នៅៈ ឈ្មោះ បៀន ហើយឥឡូវហ្នឹងនៅសំពៅលូនណោះ បាត់ដំបង ហើយអនុប្រធានឈ្មោះ តាសាន តែឥឡូវនៅសំឡូត ឃើញដាក់សាន តែមិនដឹងអីសានទេ ហើយម្នាក់ទៀតស្លាបហើយ ។

នៅៈ ស្លាប់ហ្នឹងតាឃឹម ស្លាប់បាត់ទៅហើយ ។

នៅៈ ស្លាប់ហ្នឹងកាលពីរត់ ស្លាប់បាត់ទៅ ។

នៅៈ ផ្លាស់ហ្នឹងជួនកាលគេយកទៅដាក់នៅកន្លែងមូលដ្ឋានផ្សេងទៅ ហើយម្យ៉ាងដូចថាគេសំរិតសំរាំងទៅ ថាថ្នាក់ស្រុកហ្នឹងធ្វើការងារដូចថាមិនល្អអីអញ្ចឹងទៅ គ្រាន់តែមួយជំនាន់ផ្លាស់ច្រើនណាស់គណៈ ស្រុកត្រាំកក់ ។

នៅៈ គណៈស្រុកមុនអីមិនចាំ ពីដំបូងមកមានតាជឹម និងតាគាវ ។ តាគាវហ្នឹងគេចាប់យកទៅដាក់ជ្រៃអូរក្អោទៅ ។

នៅៈ តាគាវហ្នឹង បើតាមមើលឆ្នាំ៧៦គេយកដាក់កងចល័តទៅអង្គរបុរី តាគាវ ដល់យកទៅអង្គរបុរីហ្នឹងគេហៅថាកងប្រមូលផ្តុំតំបន់ អញ្ចឹងគេយកមកដាក់នៅភ្នំសន្ទុង ក្រោយពីភ្នំសន្ទុងមកគេយកមកដាក់វិហារខ្ពស់ លាយបូរនេះ ក្រោយពីលាយបូរចុងឆ្នាំ៧៨គេយកទៅជ្រៃអូរក្អោ ស្លាប់ហើយ ស្លាប់អស់ទាំងកូនទាំងអី ប្រពន្ធនៅ កូននៅនេះ កូនហ្នឹងបាត់អស់ច្រើនដែរហ្នឹង បាត់នៅជ្រៃអូក្អោហ្នឹង ។

នៅៈ អត់ដឹងទេ ។

នៅៈ អីមិនដឹងបើតាគាវនៅភូមិនេះ នៅខាងលិចវត្តនេះ ហើយអាចសាកសួរប្រពន្ធមកវិញ យើងសួរទៅ គាត់ទៅឯណាៗ គាត់សួរពីប្រវត្តិអញ្ចឹងទៅ ដឹងរឿងនិងទៅ ប្រពន្ធគាត់ទើបតែស្លាប់ទៅ នៅកូន ។

នៅៈ តំបន់ហ្នឹងមានផ្លាស់ជាបន្តរបន្ទាប់ដែរ មិនភូមិភាគទេគឺតំបន់ តំបន់តាកែវហ្នឹង ។

នៅៈ តំបន់១៣ ប្រធានតំបន់និងមានច្រើនណាស់ ផ្លាស់ ព្រោះ២-៣ឆ្នាំដែរនិង មានហ្នឹងមិនដឹងនរណាមុននរណាក្រោយទេ មានតាប៊ិតអញ្ចឹងមក ។

នៅៈ ទេ មិនដឹងទេ លឺឈ្មោះប៊ិតៗ ។

នៅៈ តាប៊ិតហ្នឹងក្រោយគេទេ ។

នៅៈ ពីមុនមកតារ៉ន ហើយពីមុនទៀតតាមុត, តារ៉នៗ តាសោម មុនគេ តែមិនដឹងអីសោមទេណា តែសោម ហ្នឹងដូចគេចាប់យកទៅបាត់ដែរ ។

នៅៈ ទេ មិនដឹងដែរ ហើយក្រោយពីតាសោម និងមកតាប្រាក់ តាប្រាក់ហ្នឹងគេចាប់ដែរតែមិនដឹងអីប្រាក់ទេ អស់ពីតាប្រាក់ហ្នឹងមកតារ៉នៗ តារ៉ន ភ្លូកឡានបុកគ្នា រទេះភ្លើងពិបាកទៅ គេយកតាប៊ិតទៅដាក់ នៅហ្នឹង ។

នោះ ចុងឆ្នាំ ៧៨អីហើយ គាប៊ិតមកធ្វើបានបន្តិច ។

នោះ គេហៅភូមិភាគនារតីនេះ ។

នោះ គាម៉ុក ។

នោះ តែម្នាក់ហ្នឹងមិនលឺក្រៅពីហ្នឹងទៀត គេយកតំបន់ខាងសមាជិក ។

នោះ ក្រាំងតាចាន់ហ្នឹងខ្ញុំអត់និយាយកុហកទេ និយាយការពិតតែម្តង ។

នោះ អត់ដឹង គេមិនឲ្យយើងដឹងទេ ត្រឹមឃុំអី តែដល់បែកមកទៅមើលទើបឃើញព្រឹត្តិការណហ្នឹងម៉ង មានកន្លែងនៅហ្នឹងទៀត ហើយបើមេឃុំមេអី ប្រធានភូមិអីគេមិនឲ្យចូលទៅ ហើយមិនអាចដឹងទេ ព្រោះកន្លែងនេះជាកន្លែងលាក់ការណ៍សម្ងាត់របស់គេ ខ្ញុំអត់ដឹង ហើយមិនប៉ាន់ស្មានថាដល់ប៉ុណ្ណឹងផង មនុស្សបើប៉ាន់ស្មានដល់ប៉ុណ្ណឹង ម្នាក់ៗបែបមិននៅបានយូរដល់៣ឆ្នាំផង បើតាមមើល្យ

នោះ បញ្ជូន មិនដឹងជាយកទៅឯណា គេថាទៅថ្នាក់លើ យកទៅរៀនសូត្រអញ្ចឹងទៅ មានឈ្លបគេមកយកអញ្ចឹងទៅ ហៅទៅអញ្ចឹងទៅបាត់ៗទៅ ទៅបាត់ៗអញ្ចឹង យើងអត់មានអ៊ីដែលហៅថាតវ៉ា ឬស្រាវជ្រាវទេព្រោះម្នាក់ៗរកតែរួចខ្លួនដែរ ។

នោះ ឈ្មោះ សុន ស្លាប់ហើយ ។

នោះ ប្រធានតែម្នាក់ទេ ។

នោះ មិនឈ្លបឃុំទេ ឈ្លបស្រុកអី គេហៅពីនេះទៅណា ទៅដល់គេកំណត់ឈ្មោះហ្នឹងគេយកទៅ ជូនគេអត់ប្រាប់យើងផ្លូវកាត់ គេរាយការណ៍តាមខ្សែៗគេទៅ គេយកមកបាត់មក ព្រោះនេះមិនដឹងជាមានការបង្កប់របស់គេក្នុងឃុំនីមួយៗយ៉ាងម៉េចយ៉ាងម៉ាទេ ហើយបើមេឃុំម៉ងមិនដែលបានរាយការណ៍អីទេ មួយជីវិតខ្ញុំធ្វើខ្ញុំមិនដែលរាយការណ៍ថាអ្នកនេះខុសនេះៗទេ មានតែហៅមកអប់រំ អញ្ចឹងបានជានៅអញ្ចឹងបានហ្នឹងគេឲ្យធ្វើ អញ្ចឹងកន្លងមកអ្នកដែលធ្វើការនៅស្រុកហ្នឹង ធ្វើការជាមួយខ្ញុំហ្នឹងមួយគំនរគោគៗហ្នឹង ម៉េចបានជាគេឲ្យខ្ញុំធ្វើមេភូមិ គេថាខ្ញុំកាលនោះដូចជាមិនធ្ងន់ធ្ងរអី ក្នុងរបបនោះ គិតគូរពីប្រជាពលរដ្ឋ ។

នោះ ទៅពីគណៈស្រុក ស្រុកគេហៅទៅប្រជុំដាក់ផែនការ អញ្ចឹងយើងខែនេះយើងធ្វើប្រឡាយអញ្ចឹងទៅ ខែនេះយើងធ្វើសន្ទូងអញ្ចឹងទៅ ទៅតាមគម្រោងរបស់គណៈស្រុក និងបច្ចេកទេសនៅក្នុងភូមិអញ្ចឹងដែរ យើងបែកកម្លាំង កម្លាំងធំយើងធ្វើប្រឡាយទៅ កម្លាំងបន្ទាប់បន្សំយើងប្រមូលជីមក ហើយការងារតូចតាចទៀតមានរៀបចំកិនស្រូវ កិនអង្ករអីអញ្ចឹងទៅជាបន្តបន្ទាប់ ។

នោះ ខ្ញុំនៅឯស្រែរនោងណោះ ។

នោះ ៧៩ហ្នឹង និយាយរួមខ្ញុំអត់ដឹងផែនការយួនវៃចូលទេ នៅធ្វើការងារធម្មតាកំពុងច្រូតកាលហ្នឹងកំពុងច្រូតហ្នឹងនៅជាប់ជាមួយប្រជាពលរដ្ឋ ដល់វៃចូលហ្នឹងយួនហួសផ្លូវលេខ៣ទៅដល់ស្ពានស្លាគូរ

ហើយបានខ្ញុំដឹងនៅណោះ លឺតែគេវ៉ៃ ចុះពីមុនមកម៉េចហ្នឹងដឹងគេវ៉ៃគ្នា វ៉ៃនៅទល់ដែននៅព្រំប្រទល់យួនណោះ ហ្នឹងលឺអញ្ចឹងដែរ ថាចូលមកដល់ខាងត្បូងតាកែវហ្នឹងម្តងអញ្ចឹងទៅ ហើយដល់វ៉ៃថ្ងៃហ្នឹងវាdirectមកអញ្ចឹងទៅ ខ្ញុំនៅណោះដាប់ អញ្ចឹងមានប្រជាជននៅណោះ ខ្លះក៏គេឈរលើកដៃ លើកអី អញ្ចឹងអបអរសាទរហ្នឹងជ័យជំនះរំដោះ ហ្នឹងប៉ុល ពតអញ្ចឹងមក អញ្ចឹងខ្ញុំចេះតែ កាលនោះយើងខ្លាចគេដែរព្រោះយើងមេឃុំនិយាយឲ្យត្រង់ទៅ មិនមែនថាមិន ខ្លាចទេ អញ្ចឹងមកលួចចេញ មកតាមអង្គតាសោមហ្នឹង ឡានយួនទើបតែហួសមួយទៅ ខ្ញុំចេញអញ្ចឹងមក ខ្ញុំមកអង្គរការមក មកដល់អង្គរការឃើញគេរត់ដូចតែគ្នា រត់បន្ទំៗហ្នឹងគេអញ្ចឹង គ្រួសារកូនទាំងអស់នៅដាប់នៅហ្នឹងនោះ ដាប់នៅនោះមានប្រជាជនដែលគេស្រលាញ់ខ្ញុំ គេនាំកូនខ្ញុំមក អញ្ចឹង បែកគ្នាមក គេយកទៅទុកនៅចម្ការសៀងណោះ បែកគ្នាមក ២-៣ថ្ងៃទៅបានជួបគ្នាវិញ ហើយគេចៗវិលទៅវិល មកអញ្ចឹង មកផ្ទះមក ។

នៅៈ រត់ហ្នឹងរត់ហ្នឹងគេដែរ មិនមែនថា ។

នៅៈ ពេលរត់បើតាមមើលបានទៅឆ្ងាយហ្នឹងគេ ពេលខ្ញុំរត់ហ្នឹងត្រឹមនាយអាយៗហ្នឹង រត់ដើម្បីហៅថារំដោះខ្លួនចេញសិន ចាំស្តាប់សភាពការណ៍ អញ្ចឹងបែប២ខែដែរ ខ្ញុំរត់ អត់មានជួបអីទេ ជួបការលំបាកខ្វះស្បៀង ខ្វះអី ហូរហែរ ត្រូវការឈឺត្រូវការអី កូនចៅអី ។

នៅៈ មនុស្សស្លាប់អត់ទេ ២ខែខ្ញុំចេះតែវៀងចូលមក មានរវេះគោមានអី គ្រួសារចូលមុនអញ្ចឹងមក ខ្ញុំនៅភ្នំលិចនេះ ចាំស្តាប់សភាពសិន ដល់មានប្រជាពលរដ្ឋចូលហូរហែរអញ្ចឹងមក ប្រជាពលរដ្ឋខាងអង្គនរាយណ៍ថា យី! តាឯងទៅផ្ទះទៅ គ្មានអីទេ ទៅផ្ទះទៅ នៅព្រៃធ្វើអី មានបាយមានអីហូប មកលាក់ខ្លួនមុខតែហ្នឹងស្លាប់ទៅ ទៅផ្ទះទៅ តាឯងធ្វើការល្អគ្មានអីទេ មកដល់ផ្ទះអញ្ចឹង មេឃុំគេហៅទៅរៀននៅអង្គតាសោមទៅ ដាប់គុកហ្នឹងទៅ ។

នៅៈ មកហៅហ្នឹងគេទៅបាត់អស់ហើយ មិនដឹងជាទៅឆ្ងាយណាទេ ។

នៅៈ ក្នុងគុកហ្នឹង និយាយពីធ្វើការ ធ្វើធ្ងន់ មិនមែនមិនធ្ងន់ទេ ឧទាហរណ៍អញ្ចឹង ព្រលឹមឡើងអញ្ចឹងគេត្រូវការកម្លាំងទៅតាមកងគេបួនដប់នាក់ៗអញ្ចឹងទៅ ទៅធ្វើការរែកទឹក ដាំដំណាំ ពុះអុសឲ្យយួនហ្នឹង អ្នកចាស់បន្តិចទៅដាំបាយឲ្យគេទៅ ពុះអុសខ្លះទៅ ដាំបន្លែខ្លះទៅ រែកទឹកឲ្យគេផ្ទួតមួយចប់អញ្ចឹងទៅ រហូតទៅរកអុស លើងគល់អុសធំៗ សែងយកមក ពុះបណ្តើរៗទៅ បាយហ្នឹងគេឲ្យហូប អើ! មួយចានក្រហមម្នាក់ដែរហ្នឹង កំណត់មួយចានក្រហមៗម្នាក ឯម្ហូបអាហារគេឲ្យតិចតួចយើងរកផ្សំ ដូចថាធ្វើការវាលអញ្ចឹងរកបន្លែ រកត្រកួន អ្វីៗដែលស្លហូបកើតអញ្ចឹងទៅ គ្រួសារដែលទៅឲ្យលុយអី យើងទិញត្រីអីបន្តិចបន្តួចយកមកស្លហូប តាមឯកជនទេ បាយគេចែកមួយចានៗ ។

នៅៈ ប្រពន្ធកូននៅផ្ទះ ។

នៅៈ បាទ! បងប្អូនអត់ទាន់ជួបជុំទេ តែក្រុមគ្រួសារជួបជុំនៅហ្នឹងតែម្តង បងប្អូនខ្លះក៏អត់ទាន់ហ៊ានមក ខ្លះក៏នៅកន្លែងឆ្ងាយទៅ ដល់ខ្ញុំមកពីនោះវិញ បានជួបបងប្អូនទាំងអស់ អ្នកបាត់ៗដដែល អ្នកជួបហ្នឹងក៏បានជួប ។

នៅៈ ជាង៥ឆ្នាំ ថា៦ក៏បានដែរ ខ្វះតែ៤ខែ ៥ឆ្នាំនៅតែកោះអណ្តែត ។

នៅៈ ដោះលែងហ្នឹងមិនដឹងជាយ៉ាងម៉េចទេ តែម្យ៉ាងគេមកសួរប្រវត្តិរូប យើងមានធ្វើការអី កាលពីជំនាន់នោះមានការកាប់សម្លាប់អីទេ គេមានជំនាញការគេដើរស្រាវជ្រាវអញ្ចឹងដែរ ហើយកាលខ្ញុំដឹងពីទាហានមួយខ្មែរធ្វើការនៅហ្នឹងដែរ ក្រោយមកទៅផ្ទះតាឯង ទៅភូមិតាឯង ទៅរកដូងស៊ី គេថាអញ្ចឹង ថាតាឯងប្រជាជនគេចង់ឲ្យរួចច្រើនណាស់ នៅស្រែរនោង អន្តតាសោមអីគេចង់ឲ្យរួច ហើយតាឯងបានរួចហើយ អញ្ចឹងក្រោយពីនិងប្រហែលជា៣-៤ថ្ងៃមក គេហៅទៅសួរ ។

នៅៈ វ៉ៃដែរហ្នឹង ម៉េចហ្នឹងអត់ ពេលសួរចម្លើយហ្នឹងវ៉ៃម្តងហើយ តែពេលធ្វើការនៅកន្លែងហ្នឹង តែមានខុសគេវ៉ៃដែរ មិនមែនអត់ទេ មានរហូតស្លាប់អញ្ចឹងនៅក្នុងហ្នឹង ។

នៅៈ តែរបៀបនេះជាកន្លែងអប់រំ មិនមែនជាកន្លែងគេយកទៅដាក់គុក ដាក់ច្រវ៉ាក់អីទេ កន្លែងនោះគេធ្វើរោងវែងៗអញ្ចឹង យើងដេកទន្ទឹមគ្នាអញ្ចេះមក ពេលត្រូវគេឲ្យទៅធ្វើការ ពេលអត់ធ្វើការមានតែរបងនិងគេចាក់សោក្រៅទៅ គេនៅយាមក្រៅៗនិង យប់អីមានគេដាក់ភ្លើងអីឲ្យខ្លះអញ្ចឹងដែរ ពេលណាអត់ក៏អត់អញ្ចឹងដែរ តែមានរបប របបនិងកាលនោះគេថាដូច១រៀល ឬ ៧កាក់អីមិនដឹងទេ ។

នៅៈ គេវ៉ៃយើង ឧទាហរណ៍ថា យី ពួកយួនបើតាមមើល ពេលណាដែលគេថាយើងខុស តែមិនដឹងខុសអី ទៅធ្វើការអញ្ចឹងទៅ ដូចយើងខំបេះបន្លែបេះអី ខំរែកទឹកអីអញ្ចឹងទៅ គេចាប់បានគេវ៉ៃខ្លះអញ្ចឹងដែរ ក្រពះវាហេវបេះខ្លះអញ្ចឹងដែរទៅ បេះតែទ្រាំទ្រការលំបាកអញ្ចឹងទៅ គេវ៉ៃខ្លះអញ្ចឹងដែរ ត្រូវទាត់ទាត់ទៅ ត្រូវអីអីទៅ យើងមានអីតគេ យើងអ្នកទោស ។

នៅៈ ការយល់និងលំបាកដែរព្រោះការគេចាប់និង គេថាយើងនិងក្នុងរបបប៉ុលពតយើងធ្វើការងារអញ្ចឹងទៅ បានជាគេយកទៅអប់រំរៀនសូត្រអញ្ចឹងទៅ ព្រោះរបបមួយៗកាលណាចាញ់គេហើយមានទុកអី អញ្ចឹងគេមកហើយទៅរៀនសូត្រអញ្ចឹងទៅ ។

នៅៈ បាទ! តាមការយល់ឃើញថា របបកម្ពុជាប្រជាធិបតេយ្យ ការឃោសនារបស់គេមិនពិតទេ ។ មិនពិតយ៉ាងម៉េច យើងធ្វើដើម្បីប្រជាជន តែប្រជាជនលំបាកវេទនាដែរហ្នឹង ធ្វើការងារពលកម្មគ្មានពេលសំរាក ហូបមកគ្រប់គ្រាន់ ជួបជុំគ្រួសារកូនចៅមិនបានជួបជុំឲ្យស្មោះភាពបរិបូរណ៍ទេ

ហើយក្រោយ៧៩មកឃើញថាយើងនៅគង់វង្សគ្រួសារបាន វាខុសប្លែកគ្នាដែរ ការខ្វះខាតជីវភាព នេះទៅតាមកម្លាំងគ្រួសារនីមួយៗដាក់ស្តែងទេ ។

នៅៈ និយាយមិនជឿយ៉ាងម៉េច បើឃើញនិងភ្នែក ។

នៅៈ ទេ ពិបាកយល់ដែរអារឿងសម្លាប់ហ្នឹងខ្ញុំមិនយល់សោះកាលពីជំនាន់នោះ មិនដឹងយ៉ាងម៉េចលឺថារៀនសូត្រ លឺថារៀនសូត្រ ហើយបាត់អញ្ចឹងទៅមានការសម្លាប់អញ្ចឹង ផែនការនេះជាផែនការសម្ងាត់របស់គេខាងលើ គេអត់ប្រាប់យើងក្រោមៗទេ ដឹងថាឡើងទៅរៀនសូត្រ ឡើងទៅរៀនសូត្រ ខ្ញុំលឺមិនបានដឹងយ៉ាងម៉េចយ៉ាងម៉ាទេ តែដឹងថាអ្នកនិងប្រឆាំង ទំនាស់ជាមួយបក្សគេអញ្ចឹងទៅ គេយកទៅបាត់ៗអញ្ចឹងទៅ ។

នៅៈ បាទ! លឺតែអត់ដែលជួបទេ ។

នៅៈ លឺគេថា ប៉ុល ពត, អៀង សារី, ខៀវ សំផន តែមុខមាត់អី ។

ភារិទ្ធៈ លឺក្នុងសម័យពាន្ឆាំហ្នឹងម៉ងហេះ?

នៅៈ បាទ!

នៅៈ ដឹង ព្រោះវិទ្យុគេផ្សាយដែរ ប៉ុល ពត លេខាបក្ស នាយករដ្ឋមន្ត្រី អៀង សារី ឧបនាយករដ្ឋមន្ត្រី និងក្រសួងការពារប្រទេស ។

នៅៈ ការបរទេស ហើយខៀវ សំផន គណប្រធានរដ្ឋ ។

នៅៈ ក្រៅពីហ្នឹងទៀតមិនប្រាកដទេ ព្រោះគេនិយាយខាងលើៗហ្នឹងមក ។

នៅៈ នួន ជា គេថាអនុប្រធាន លឺតែមិនសូវលឺឲ្យវាខ្ទរខ្ទារទេ បើ អៀង សារី, ខៀវ សំផន, ប៉ុល ពត ហ្នឹងលឺ ។

នៅៈ សុន សេន លឺខ្វះដែរ ។

នៅៈ មិនប្រាកដទេ កាលហ្នឹងដូចមិនសូវដឹងច្បាស់ដែរ ។

នៅៈ ហ៊ឺស! អង្គការហ្នឹងពិបាកណាស់ តែត្រឹមឃុំឡើងទៅអង្គការហើយ តែអង្គការហ្នឹងអ្នកទទួលខុសត្រូវ រួមនៅមជ្ឈមហ្នឹងណា ហ្នឹងគេហៅថាអង្គការហើយ តែដល់យូរវាឲ្យតែឃើញអង្គការទាំងអស់ ត្រឹមមេភូមិហ្នឹងអង្គការទៅ មេឃុំទៅក៏អង្គការទៅ គណៈស្រុកក៏អង្គការ តំបន់ក៏អង្គការឲ្យតែឃើញគឺថាអង្គការមកហើយ ពាក្យអង្គការហ្នឹងដូចថាអ្នកគ្រប់គ្រងទៅវិញ ជំនាន់នោះគេយកអញ្ចឹង នេះប្រជាពលរដ្ឋគេឲ្យឈ្មោះទេ ។

នៅៈ អត់បានដឹងទេ ស្លាបហ្នឹងលឺគេផ្សាយថាប៉ុល ពតស្លាប់អញ្ចឹងទៅ ខៀវ សំផន អៀង សារីហ្នឹងចូលមក សមាហរណកម្មនេះ ហ្នឹងលឺតែអញ្ចឹង តែមិនដឹងនៅឯណាអីហ្នឹងមិនដឹងទេ ។

នៅៈ តា ម៉ុកនិងខាងរាជរដ្ឋាភិបាល តែមិនដឹងនៅឯណាដែរ ។

ភារិទ្ធៈ តែកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យធ្លាប់ជួបគាត់ដែរ?

នៅៈ ជួប ។

នៅៈ ជួបនៅតាកែវ ព្រោះយើងខាងឃុំទាំងអស់ត្រូវឡើងទៅធ្វើសន្និបាតក្នុងមួយខែម្តងនៅភូមិភាគតាម៉ុកជួប ។

នៅៈ ភូមិភាគនៅតាកែវ ។

នៅៈ មិនមែនទេ ជួបហ្នឹងកន្លែងរៀនផ្ទះខាងជើងវត្តពីដើម ហ្នឹងមានសាលាហ្នឹងនៅ ហើយមកដេកនៅកន្លែងគរុកោសល្យឥឡូវនេះ នៅផ្ទះបារាំង គេហៅថាផ្ទះបារាំងៗ ទៅរៀននៅហ្នឹងជួប មិនមែនថាមិនជួបទេ ។

នៅៈ អត់មានយល់ទេ ហ្នឹងគេធ្វើទៅតាមច្បាប់ ច្បាប់គេយកទៅកាត់ទោសម៉េច ហ្នឹងតាមដំណើរគេអញ្ចឹង បើថាមានចិត្តអារម្មណ៍អី ទោះខ្ញុំធ្វើការអញ្ចឹងបើគេកាត់ទោសខ្ញុំក៏អត់មានបញ្ហាអីដែរ ហ្នឹងកាលកន្លងមក ការធ្វើត្រឹមភូមិត្រឹមឃុំ អានេះធ្វើតាមរបបគេ កាលនោះបើយើងអត់ធ្វើក៏គេថាយើងប្រឆាំងដែរ ឧទាហរណ៍ថាឲ្យខ្ញុំធ្វើអញ្ចឹង បើយើងប្រកែកមិនធ្វើ គេថាយើងប្រឆាំងគេផាប់អាសារបង់ ។

នៅៈ ថាម៉េច ថតរូប ថតធ្វើអី ។

នៅៈ ថតធ្វើអី ។

នៅៈ មិនបាច់ថតទេអី ។

នៅៈ អត់អារម្មណ៍អីទេ តែកាលពីមុនក៏អត់ឲ្យថតអញ្ចឹងដែរ ថតមិនបានទេ បើដាក់សម្ភាសន៍អី ដាក់ម៉ាញ៉ែអី និងខ្ញុំនិយាយតាមដាក់ស្តែងហ្នឹង ។

នៅៈ អត់មានបារម្ភអីទេ អានេះសម្ភាសន៍នៅក្នុងនេះហើយ ជាប់ក្នុងនេះហើយ ស្គាល់ហើយ បើថតទៀតមិនបាច់ទេ ឃើញរូបភាព ព្រោះពីមុនខ្ញុំអត់ឲ្យថតអញ្ចឹងដែរ ថតម៉ាញ៉ែបាន ។

ភារិទ្ធៈ អត់អីទេអញ្ចឹង?

នៅៈ បាទ ។

នៅៈ លឺហ្នឹងជាហូរហែរមកហើយ ។

នៅៈ ឆ្នាំហ្នឹងមិនអាចកំណត់បានទេ បែបខ្វង់៣ឆ្នាំហើយមិនដឹង គ្រាន់តែលឺៗអញ្ចឹង ក្តាប់តាមវិទ្យុទូរទស្សន៍អីហូរហែរ តែឃើញតែនៅប៉ុណ្ណឹងដដែល ។

នៅៈ រឿងកាត់ទោសហ្នឹង បើតាមខ្ញុំស្តាប់ហ្នឹងការគិតគូរក្នុងចិត្តទៅ វាទាក់ទិនហ្នឹងថវិការដែរ តែកាត់ទោសវាត្រូវហើយ តែសំខាន់ការកាត់ទោសវាត្រូវមានមេធាវី មានចៅក្រម មានតុលាការអី

អន្តរជាតិរួមផ្សំហ្នឹងតុលាការខ្មែរអញ្ចឹង វាត្រូវការថវិការ អញ្ចឹងបានជាការរអាក់រអួលប្រហែលមកពីថវិការហ្នឹងហើយយ៉ាង ហើយយ៉ាងម៉េចយ៉ាងម៉ាខ្ញុំមិនអាចវិភាគឲ្យខុសទេ ។

នៅៈ ហ្នឹងខ្ញុំមិនអាចសន្និដ្ឋានបានទេ ។

នៅៈ អានេះជាច្បាប់ ខ្ញុំមិនអាចសន្និដ្ឋានបានទេ អានេះធ្វើទៅតាមកិច្ចការរបស់អ្នកដឹកនាំទេ ខ្ញុំមិនអាចកំណត់ថាជាសំខាន់ឬមិនសំខាន់ ហ្នឹងខ្ញុំមិនហ៊ានថាទេព្រោះសំរេចខាងលើ កំណត់យ៉ាងម៉េចហ្នឹងទៅតាមដំណើរហ្នឹងទៅ ។

ភារិទ្ធៈ ចុះអ៊ំ មេដឹកនាំសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង អ៊ំគួរតែអត់ទិនទោសដែរអត់ទេ?

នៅៈ ទេ ក៏មិនហ៊ានថាដែរ ។

នៅៈ ទេ ក៏មិនហ៊ានថាដែព្រោះអានិងវានៅលើច្បាប់ ព្រោះកំណត់ម្នាក់ម៉េចត្រូវ ក្នុងច្បាប់របស់គេ ។

នៅៈ ហ្នឹងក៏មិនហ៊ានថា ព្រោះមិនហ៊ានថាដូចខ្ញុំបានជម្រាបព្រោះយើងមិនមែនជាអ្នកច្បាប់ ហើយមិនជាតុលាការ វិនិច្ឆ័យក៏អត់ចេញដែរ ។

នៅៈ បាទ! នេះមិនជាការសងសឹកទេ នេះជាច្បាប់របស់ប្រទេសនីមួយៗ អ្នកណាដែលប្រព្រឹត្តិខុសគេត្រូវតែធ្វើតាមហ្នឹង ហ្នឹងចេះច្បាប់ក្រោយ គេត្រូវតែធ្វើអញ្ចឹង ។

នៅៈ មិនហ៊ានថាទេ មិនហ៊ានថាព្រោះយើងមិនអាចដឹងបាន ។

នៅៈ ហ្នឹងអត់បានដឹងគម្រោង មិនហ៊ានថារកឃើញ ឬមិនឃើញទេ ។

នៅៈ ពិបាកនិយាយណាស់ ពាក្យថាយុត្តិធម៌ហ្នឹងសន្និដ្ឋានថា យុត្តិធម៌ក៏មិនការពិត អយុត្តិធម៌ក៏មិនការពិតដែរ ព្រោះកាលជំនាន់នោះ អំពើរដែលកាប់សម្លាប់ហ្នឹង យើងមិនដឹងពីបំណងហ្នឹងផែនការរបស់គេ អញ្ចឹងបានថាពិបាកសន្និដ្ឋានទៀតនៅលើរឿងហ្នឹង ថាពិតក៏បាន ថាពិតក៏មិនបាន ថាអយុត្តិធម៌ក៏មិនបាន យុត្តិធម៌ក៏មិនបានព្រោះរបបគេ ។

នៅៈ ការផ្សះផ្សាបង្រួបបង្រួមជាតិបើតាមទស្សនៈខ្ញុំផ្ទាល់ខ្ញុំថាល្អ ។

នៅៈ ដើម្បីកុំឲ្យជាតិប្រេះឆាហ្នឹងគ្នា កុំឲ្យហៅថាម្នាក់ទៅម្នាក់ហ្នឹងគេចេះតែចង់សងសឹកគ្នាទៅវិញទៅមកការសងសឹកហើយនាំឲ្យសង្គ្រាមជាហូរហែរបន្តរបន្ទាប់មក ដល់ការបង្រួបបង្រួមជាតិចូលគ្នាអញ្ចឹងទៅ ហ្នឹងការរីកចំរើនចេះតែមានហើយ បើថាការនៅចេះតែគុំគួនគ្នា សងសឹកគ្នា ថាអ្នកនេះអញ្ចេះ អ្នកនោះអញ្ចោះការនោះមិនល្អទេ នាំតែបែកបាក់សាមគ្គី ហើយកាលណាបែកបាក់សាមគ្គីអាចមានគ្រោះមហន្តរាយ ។

នៅៈ ការកាត់ទោសហ្នឹងបើវិភាគទៅមាន២ មួយគឺៈ គេរកយុត្តិធម៌ដើម្បីប្រជាជន ប្រជាពលរដ្ឋហើយមួយទៀត កាលណាយើងធ្វើការបង្រួបបង្រួមជាតិអញ្ចឹងហើយ សមាហរណកម្មអញ្ចឹងដល់មកមានការកាត់ទោសអីអញ្ចឹង អ្នកដែលតាមការអំពាវនាវរបស់រាជរដ្ឋាភិបាលឲ្យចូលមករួម

ហើយ ហើយយកមកកាត់ទោស ហ្នឹងវាអាចប៉ះពាល់ដែរ ប៉ះទង្គិចដល់អារម្មណ៍ដែរ ដល់តែយូរលែងជឿថា យី! មិនទុកចិត្តគ្នាទៅវិញទៅមកអញ្ចឹង ហ្នឹងខុសគោលនយោបាយរបស់រាជរដ្ឋាភិបាលដែរ អ្នកដែលធ្វើសមាហរណកម្មមកហ្នឹង គឺអនុវត្តិពាក្យស្លោករបស់នាយករដ្ឋមន្ត្រីថា "ឈ្នះ ឈ្នះ សុទ្ធតែអ្នកឈ្នះ គ្មានអ្នកចាញ់" ហ្នឹងល្អនយោបាយហ្នឹងគឺល្អ ។

នៅៈ បាទ! ហ្នឹងខ្ញុំមិនអាចសន្និដ្ឋានបានទេ ។

នៅៈ រឿងបំបាត់សាសនាហ្នឹង ខ្ញុំកាលពីជំនាន់នោះការនឹកឃើញចេះតែនឹកឃើញហើយព្រោះយើងធ្លាប់ខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនា អញ្ចឹងដាក់រាជរដ្ឋាភិបាល ជាតិសាសនា ព្រះមហាក្សត្រ ហ្នឹងតាំងពីជំនាន់សម្តេចនៅមកម្ល៉េះ តែដល់ខ្មែរក្រហមកាន់កាប់មកហ្នឹង ពុទ្ធសាសនារលាយទៅជាបន្តបន្ទាប់ ចិត្តមិនជ្រះស្រឡះដែរនិយាយរួមព្រោះយើងអ្នកបួស អ្នករៀន អ្នកកាន់ព្រះពុទ្ធសាសនា អញ្ចឹងចិត្តមិនជ្រះស្រឡះទៅ តែធ្វើម៉េចដែនការរបស់រដ្ឋាភិបាលទៅហើយធ្វើម៉េចយើងហ្នឹងហ៊ានថា យើងហ៊ានថាយើងប្រឆាំង ។

នៅៈ បាទ! ខ្ញុំមិនបានដឹងទេ មិនបានដឹងស៊ីជម្រៅដល់ហ្នឹងទេ ព្រោះហ្នឹងនិយាយតាមជាក់ស្តែងទៅ មិនដឹងគោលបំណងស៊ីជម្រៅដល់ហ្នឹងមិនអាចនិយាយបានទេ ។

នៅៈ ហ្នឹងវាល្អ ។

នៅៈ ឧទាហរណ៍ថាអ្នកដែលធ្វើខុស ប្រព្រឹត្តនៅអំពើអ៊ីមួយ ហើយអ្នកដែលមិនចងពៀរមកវិញ ការធ្វើហៅថាមនុស្សធម៌ល្អណាស់ ពៀរមិនចងពៀរ ឃើញគេខុសយើងអត់ហៅថាអត់ប្រកាន់ អត់ឈ្នានីសអីទេ គឺយើងរាប់អានគ្នាអញ្ចឹងទៅ សាមគ្គីសាមគ្គាគ្នាល្អប្រពៃណាស់ ។

នៅៈ ទេ! បើកាលព្រះពុទ្ធគង់នៅបាន បានថាឥឡូវមិនហ៊ានថា បើកាលពីព្រះពុទ្ធនៅគង់នៅ ឧទាហរណ៍ថាអ្នកខុស ឧទាហរណ៍ថា អង្គុលីមាអញ្ចឹងសម្លាប់មនុស្ស៩៩៩នាក់ហើយ ដើម្បីយកមកប្រសិទ្ធិឲ្យជាអទិទេពខ្ពង់ខ្ពស់ រកអ្នកប្រៀបផ្ទឹមមិនបានទេកាលហ្នឹង នោះអង្គុលីមានៅក្នុងសៀវភៅមានហើយ អញ្ចឹងព្រះពុទ្ធលោកប្រោសបានតើ អង្គុលីមា ប្រោសបាន ហ្នឹងល្អហើយ យុត្តិធម៌ដែរអ្នដែលធ្វើខុសហើយ ក្រោយពីព្រះពុទ្ធបានសំដែងធម៌ទេសនា មានការភ្ញាក់រលឹកដឹងខ្លួនមកកសាងក្នុងព្រះពុទ្ធសាសនាវិញគឺល្អណាស់ ។

នៅៈ បច្ចុប្បន្ននេះចំពោះអ្នកធ្វើការក្នុងរាជរដ្ឋាភិបាលបច្ចុប្បន្ន និងអ្នកពាក់ព័ន្ធនិងខ្មែរក្រហមហ្នឹងឃើញមានសាមគ្គីគ្នា ល្អដោយមិនប្រកាន់គ្នា ហៅថាមិនចាប់ផ្ដាក់គ្នា ឬស្អប់ខ្ពើមទេ ឧទាហរណ៍ខ្ញុំជាក់ស្តែងអញ្ចឹង ធ្លាប់ធ្វើការកន្លងមកជួបបងប្អូនរួមរស់អីកាលពីជំនាន់ប៉ុល ពតអី មានការរាប់អានខ្ញុំនេះជាបន្តបន្ទាប់ រហូតដល់ខ្ញុំនេះទៅទាក់ទងមកធ្វើកឋិននៅអង្គរនាប អ្នកដែលធ្វើការរកស៊ីមាន

បានហ្នឹងមកហូរហែរអញ្ចឹង អញ្ចឹងឃើញធម្មតា ការរាប់អានហ្នឹងធម្មតា ដូចជាគ្មាននឹកឃើញអ្នកនេះនៅជំនាន់នេះ អ្នកនោះនៅជំនាន់នោះទេ អត់ ។

នៅៈ អត់ទេ ។

នៅៈ និយាយកាលណានិយាយវាទាស់ជាមួយរាជរដ្ឋាភិបាល បើអញ្ចឹងអត់មាននិយាយគឺកូនចៅដែលកើតក្រោយៗហ្នឹងក៏មិនដឹងថាខ្ញុំនិងធ្វើអីដែរកាលពីជំនាន់នោះ អញ្ចឹងអត់មាននិយាយប្រាប់ទេ ។

នៅៈ និយាយដូចថា និយាយអញ្ចឹងទៅ យើងដឹងពីរបប របបនោះយើងផ្តួលរលំហើយនៅលើកមកធ្វើអីទេ ហ្នឹងយើងកប់ចោល ព្រោះរបបហ្នឹងអស់សិទ្ធិយើងលើកមកធ្វើអី យើងនិយាយធ្វើអី ។

នៅៈ ហ្នឹងបើតាមគំនិតខ្ញុំគួរឲ្យមានដែរហ្នឹង ឲ្យក្មេងវាដឹង ក្នុងជំនាន់នេះសម័យនេះ អ្នកណាធ្វើយ៉ាងម៉េចយ៉ាងម៉ា ហ្នឹងត្រូវដឹង ហ្នឹងសំខាន់ស្រេចលើរដ្ឋាភិបាល ។

នៅៈ ការដឹងហ្នឹងវាមានហើយ អត្ថន័យនិង អត្ថប្រយោជន៍ហ្នឹងវាមានណាស់ ម្យ៉ាងយើងដឹងអំពីព្រឹត្តិការណ៍ក្នុងដំណាក់កាលនីមួយៗដែលប្រជាជនកម្ពុជាជួបប្រទះនូវឧបសគ្គបែបណា ជួបហ្នឹងការលំបាកបែបណា ជួបហ្នឹងការស្រួលបែបណា ហ្នឹងយើងត្រូវតែមាន បើតាមគំនិតខ្ញុំទេណាត្រូវតែមាន ហើយត្រូវតែឲ្យដឹង ។

នៅៈ ហ្នឹងយើងលែងជឿហើយ កាលណាលែងជឿហើយ មិនអាចត្រឡប់បានទេ សំខាន់យើងម្នាក់ៗប្រជាពលរដ្ឋទូទាំងប្រទេស លែងជឿហ្នឹងរបបកម្ពុជាប្រជាធិបតេយ្យហើយ និងមិនអាចមកវិញបានទេ ព្រោះអស់ជំនឿ ។

នៅៈ ដូចខ្ញុំជម្រាបម៉ិញហើយថាខ្ញុំមិនដែលនិយាយ អត់ដែលនិយាយម៉ង មិនហ៊ាននិយាយ ។

នៅៈ ទេ ដូចជាអត់ទេ ព្រោះរបបហ្នឹងវាបរាជ័យហើយ ដឹងរំលឹកមកធ្វើអីទេ ។

នៅៈ កន្លងមកខ្ញុំមិនដែលមានរឿងក្តីក្តាំងអីទេ តែអ្នកដែលធ្លាប់ក្តីក្តាំងហ្នឹងវាមានហៅថា មានការយុត្តិធម៌ហ្នឹងល្អខ្លះ តែរឿងអាក្រក់ហ្នឹងក៏មានខ្លះដែរ មិនបានជាស្អាត ១០០ភាគរយទេ មានល្អអាក្រក់តិចតួច នៅតែមានទៅតាមបុគ្គល ។

នៅៈ រឿងហ្នឹងពិបាកនិយាយណាស់ ។

នៅៈ តាមគំនិតហ្នឹងនិយាយទៅវាខុសគម្រោងរបស់រាជរដ្ឋាភិបាល ហ្នឹងមិនអាចសន្និដ្ឋានបានទេ តែចិត្តគំនិតម៉ងចង់បានឲ្យល្អ ហើយថាឲ្យល្អគ្រប់កន្លែងអញ្ចឹងទៅ ធ្វើអីឲ្យល្អដើម្បីជាតិ ធ្វើអីក៏ដើម្បីជាតិទេ ហ្នឹងគឺអញ្ចឹង ។

នៅៈ ទេ! ការនឹកឃើញហ្នឹងនឹកឃើញមិនអត់ទេ នឹកឃើញស្តាយដីស្រែ ស្តាយដីចម្ការ ផ្ទះសំបែងអីនៅតែមានការនឹកឃើញដែរហ្នឹង មិនអត់ទេ ។

នៅៈ មានតើ ការឈឺចាប់យើងធ្វើប្រធានឃុំក៏យើងឈឺចាប់ម្យ៉ាងមិនបានជួបម្ដាយ ម្យ៉ាងមិនបានជួបបងប្អូន ញាតិមិត្តអីដូចកាលយើងនៅនេះ ។

នៅៈ ហ្នឹងមិនដឹងដោះស្រាយវិធីអីទេ យើងដូចថាបំភ្លេចចោលអញ្ចឹងទៅ វាអារម្មណ៍ហ្នឹងអត់នេះ ។

នៅៈ បាទ! តាមសាសនាអាចបាន ។

នៅៈ ដោយម្យ៉ាងយើងគិតតែពីបុណ្យកុសលផលទានយើង យូរៗទៅភ្លេចរបបហ្នឹងបាត់ហើយ សន្សំតែកុសលទៅ យើងស្អប់រំងាប់ ភ្លើងទុក្ខ ភ្លើងកិលេសដូចក្មួយថាពៀរមិនចងពៀរអញ្ចឹងបាត់ទៅ ។

នៅៈ នេះបើនិយាយទៅមាន២ បើគិតតាមព្រះពុទ្ធសាសនា ព្រះអង្គសម្ដែងមកហ្នឹងជាកម្មពៀរ គេហៅថាព្រហ្មលិខិតរបស់មនុស្ស តែបើគិតពីច្បាប់រដ្ឋហ្នឹងមិនមានអញ្ចឹងទេ ហ្នឹងថាការរំលោភ ឬការបំពានសិទ្ធិដើម្បីអំណាច ដើម្បីរបបហ្នឹងអញ្ចឹង ។

នៅៈ ម៉េចទេហ្នឹងពិបាក ។

នៅៈ បាទ! ចង់ដឹងដែរ មិនមែនថាមិនចង់ទេ ។

នៅៈ ការយល់របស់ខ្ញុំគឺស្វែងរកការពិតដើម្បីជូនជាតិ ជូនប្រទេស ជូនប្រជាពលរដ្ឋ និងការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យអញ្ចឹង ។

នៅៈ បាទ! ការពិតខ្លះ មិនពិតខ្លះដែរ ខ្លះនិយាយដូចថាការពិតហ្នឹងនិយាយជារូបភាពអីអញ្ចឹង ដូចនិយាយអីអញ្ចឹង ពិតទៅ ឧទាហរណ៍ថារូបភាពអញ្ចឹងទៅពិត នេះជាការពិត តែខ្លះដូចថាយើងបញ្ចូលបច្ចេកទេសអីខ្លះ បន្ថែមអីខ្លះនិងក៏មិនមែនជាការពិតដែរ មិនអញ្ចឹង ។

នៅៈ អត់ទេ នេះច្បាប់ដែរមានអង្គការក្រៅរដ្ឋាភិបាលដែលត្រូវចេះពិនិត្យអញ្ចឹង ហ្នឹងមានទុកចិត្តយ៉ាងម៉េច តែម្យ៉ាងសំខាន់គឺអត់ឲ្យហៅថាវិក័យបត្រអីសម្គាល់ទីតាំងអីផង ។

នៅៈ អត់មានថាមានអីឲ្យច្បាស់លាស់ណា៎ សៀវភៅនេះចេះតែយកមកឲ្យទៅអញ្ចឹង ។

នៅៈ បើមានលិខិតបញ្ជាក់ច្បាស់អសយដ្ឋានអី នាមប័ណ្ណណា៎ ។

នៅៈ ក្មួយកាលពីមកមុនសុទ្ធតែនារីៗ តែមកអញ្ចឹងគេឲ្យក្រដាស់ ។

នៅៈ សួរថាឲ្យថតដែរអត់ ថាបើថតក៏ថត អត់ក៏អត់ទៅ សំខាន់អត់ទៅ អត់ថតដែរ នារីៗហ្នឹងអត់ថតទៅ ហ្នឹងតាមស្ម័គ្រចិត្តអញ្ចឹងដែរនិង ដូចថ្ងៃហ្នឹងអញ្ចឹង ។

នៅៈ ចុះមានបញ្ហាអី មានសៀវភៅអញ្ចឹងចេះតែមានមានហើយ មកពីណាមក ដល់នេះយកទៅបង្ហាញអញ្ចេះអញ្ចោះ ។ ក្មួយមកថ្ងៃមុនមានវិក័យបត្រនិងប្រហែលជាខ្ចីដែរ មជ្ឈមណ្ឌលស្រាវជ្រាវការពិតហ្នឹងមានតើ ។

ចប់